# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## នាយកក្រុមហ៊ុន ហ័រសេងដា ហ្ស៊ីបភើ(ខេម)ខូអិលធីឌី

## កិច្ចព្រមព្រៀង

នៅព្រឹកថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០២០ នៅក្រុមហ៊ុន **ហ័រសេងដា ហ្ស៊ីបភើ (ខេម)** បានបើកកិច្ចប្រជុំមួយរវាង ប្រធានរោងចក្រ ជាមួយតំណាងកម្មករក្នុងក្រុមហ៊ុន នឹងប្រធានក្រុមគ្រប់ផ្នែក ស្ដីពីការស្នើរសុំព្យួរកិច្ចសន្យាការងារ។

**កម្មវត្ថុ៖** សំណើរស្នើរសុំព្យួរកិច្ចសន្យាការងាររបស់កម្មករ និយោជិត។

**យោង៖** តាមមាត្រា ៧១ និងមាត្រា ៧២ នៃច្បាប់ស្ដីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ។

យោងតាមសេចក្ដីប្រកាសរបស់ក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈលេខ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ស។

សេចក្ដីដូចមានចែងក្នុង កម្មវត្ថុ និង យោង ខាងលើនេះ ដោយសារតែរោងចក្រយើងខ្ញុំត្រូវបានលុបចោលការបញ្ជាទិញ និងគ្មានការបញ្ជាទិញពីអតិថិជន ដែលទាក់ទងនិងប៉ះពាល់ពីជម្ងឺរលាកផ្លូវដង្ហើម (COVID-19)។ ដូច្នេះក្រុមហ៊ុនយើងខ្ញុំស្នើរសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ៥៥ នាក់រយៈពេល ២ ខែ ដោយគឹតចាប់ពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០២០។

ដោយយោងតាមមាត្រា និង ប្រកាស ខាងលើ ភាគីទាំងអស់គ្នាបានឯកភាពគ្នាព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០២០ រហូតដល់ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០២០។ ក្រុមហ៊ុនយល់ស្របតាមគោលការណ៍រាជរដ្ឋាភិបាលក្នុងការផ្ដល់ឧបត្ថម្ភ ៣០ ដុល្លា អាមេរិចក្នុង ១ខែ ជូនដល់កម្មករនិយោជិត ដោយអនុវត្តតាមប្រកាសរបស់ក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈលេខ ០៤៥/២០ ក.ប/ស.ណ.ន.ខ.ស។

កិច្ចប្រជុំបានចប់សព្វគ្រប់នៅថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសសប្បាយរីករាយ។ ភាគីទាំងសងខាងបានឯកភាពគ្នាអនុវត្តលើកិច្ចព្រមព្រៀង និង សូមផ្ដិតមេដាយ ចុះហត្ថលេខា ទុកជាភស្តុតាងដូចខាងក្រោម។

ថ្ងៃ ច័ន្ទ ១៤កើត ខែ ស្រាពណ៍ ឆ្នាំ ជូត ទោស័ក ពស ២៥៦៤

កំពង់ស្ពឺថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០២០

**នាយកក្រុមហ៊ុន**

**ស្នាមមេដាយតំណាងកម្មករ**

ទូច ទឹត    នៅ ស្រីអូន

ក្រុមហ៊ុន ហ័រសេងដា ហ្ស៊ីបភើ(ខេម)
រដ្ឋបាល+ធនធានមនុស្ស
Admin & HR Department
HUASHENGDA ZIPPER (CAM) CO., LTD.